ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៦៩០ សណ.១៥ អអក

ភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់លើការបញ្ចុះអត្រាថ្លៃលក់អគ្គិសនីនៅក្នុង តំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប នៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ខេត្តកោះកុង

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប មេត្តាជ្រាបថា កន្លងមកក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប គឺជាក្រុមហ៊ុនបាននាំចូលប្រភពអគ្គិសនីពីប្រទេសថៃតាមខ្សែបណ្តាញ ២២គីឡូវ៉ុល មកចែកចាយឲ្យអ្នកប្រើប្រាស់នៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលបច្ចុប្បន្ន មានថ្លៃលក់រាយជូនប្រជាពលរដ្ឋក្នុងអត្រា ៦,៥ បាតក្នុង១គីឡូវ៉ាត់ម៉ោង ។ យោងតាមការរីកចម្រើនលើវិស័យឧស្សាហកម្មពាណិជ្ជកម្ម បានធ្វើឲ្យកំណើនថាមពលប្រើប្រាស់កើនឡើង ហើយអាជ្ញាធរអគ្គិសនីកម្ពុជាបានធ្វើការពិនិត្យគណនា វិភាគថ្លៃដើមអគ្គិសនីសម្រាប់ធ្វើសេវាកម្មរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប ឃើញថា ថ្លៃដើមអគ្គិសនីចែកចាយបានថយចុះមួយចំនួន អាចបន្ថយថ្លៃលក់បច្ចុប្បន្នបាន។ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងបញ្ចុះអត្រាថ្លៃលក់របស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប មកអត្រាថ្លៃលក់ថ្មី ដូចខាងក្រោម ៖

| ប្រភេទប្រើប្រាស់ | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនទូទៅ ទិញលើតង់ស្យុងទាប | ៦ បាត/គ.វ.ម៉ |
| អតិថិជនឧស្សាហកម្ម-ពាណិជ្ជកម្ម ទិញអគ្គិសនីលើតង់ស្យុងមធ្យម | ៥,៨ បាត/គ.វ.ម៉ |

ដើម្បីឲ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឲ្យក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់ទាំងអស់ ដែលពាក់ព័ន្ធនឹងថ្លៃនេះ សូមមេត្តាពិនិត្យ ផ្តល់មតិលើឯកសារគណនាវាយតម្លៃការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ ។ ក្រោយថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៥ គម្រោងកែសម្រួលថ្លៃលក់អគ្គិសនីនេះ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តកែសម្រួលអត្រាថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ថា ការផ្តល់យោបល់លើឯកសារគណនា វាយតម្លៃ ដែលភ្ជាប់មកជាមួយ សូមមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចពិនិត្យបាន ទៅតាមការ

កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ និងត្រូវរក្សាបាននូវតុល្យភាពយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកផ្គត់ផ្គង់អគ្គិសនីផង ។

ឯកសារកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឲ្យក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ ........................................................................................................................ ..........សម្រាប់សាធារណជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់មតិយោបល់ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**